រដ្ឋាភិបាល ឆ្លើយតបចំពោះការធ្លាយហៀរប្រេងក្រុមហ៊ុនអង់គ្លេស BP

ទស្សនៈលើតំមានថ្មីៗ នៅតាមឆ្នេរឈូងសមុទ្រ សូមមើលលើគេហទំព័រ http://www.epa.gov/bpspill

បច្ចេកទេសដែលមានការផ្លាស់ប្តូរ

កក្កដា 2010

កម្មវិធីវាយតម្លៃបច្ចេកទេសរវាងទីភ្នាក់ងារដែលប្រកបដោយជម្រើស

ទីភ្នាក់ងារការពារបរិស្ថាន EPA បានចូលរួមជាមួយទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត នៅក្នុងកម្មវិធីវាយតម្លៃបច្ចេកទេសរវាងក្រុមទីភ្នាក់ងារដែលប្រកបដោយជម្រើស (IATAP) ដំណើរការដែលបានធ្វើមជ្ឈការមួយ សម្រាប់ប្រជាពលរដ្ឋ ឧស្សាហកម្ម និង អ្នកលក់ដូរ ដើម្បីបញ្ជូននូវដំណោះស្រាយខាងបច្ចេកវិជ្ជាដែលអាចធ្វើទៅ បានសម្រាប់ការឆ្លើយតបច្ចេកទេសនៅក្នុងតំបន់ចំនួនប្រាំ: ការធ្វើឱ្យប្រសើរឡើងសម្រាប់ការវិនិច្ឆ័យប្រេង ចំពោះការឆ្លើយតប និង ទិសដៅការត្រួតពិនិត្យក្បាលគំរបអណ្តូងប្រេង និង ការឆ្លើយតបប្រេងលិចក្នុងទឹកសមុទ្រ បច្ចេកទេសនៃការឆ្លើយតបប្រេងធ្លាយហៀរតាមរបៀបបុរាណ បច្ចេកទេសនៃការឆ្លើយតបប្រេងធ្លាយហៀរតាមជម្រើសផ្សេងៗ និង ការវាយតម្លៃលើការខូចខាតដោយសារប្រេងធ្លាយហៀរ និង ការថែរក្សាប្រេង។ ទីភ្នាក់ងារការពារបរិស្ថាន EPA មានការទទួលខុសត្រូវជាបឋម ចំពោះការត្រួតពិនិត្យឡើងវិញអំពីការបញ្ជូនបច្ចេកទេសនានា ដែលបានវិនិច្ឆ័យ "បច្ចេកទេសនៃការឆ្លើយតបប្រេងធ្លាយហៀរតាមជម្រើសផ្សេងៗ" ដែលរួមមាន ការដុតឱ្យឆេះនៅនឹងកន្លែង ការធ្វើប្រព្រឹត្តិកម្មគីមី និង ការធ្វើជីវិសាស្ត្រតាមជម្រើសផ្សេងៗ និង ការប្រើប្រាស់តាមវិធីកែច្នៃថ្មីៗ មិនត្រូវបានគេយកមកប្រើប្រាស់ជាទូទៅ សម្រាប់ការឆ្លើយតបប្រេងធ្លាយហៀរនេះឡើយ។

នៅពេលជាមួយគ្នានេះ ការបញ្ជូនបច្ចេកទេស ដើម្បីបានទៅដល់ទីភ្នាក់ងារការពារបរិស្ថាន EPA វាត្រូវបានវាយតម្លៃយ៉ាងឆាប់រហ័ស ដោយក្រុមអ្នកជំនាញបច្ចេកទេសដែលសមស្របមួយ។ បន្ទាប់មក អ្នកជំនាញ EPA ធ្វើចំណាត់ថ្នាក់លើរាល់ការបញ្ជូនមកនេះ ដូចជា អាចដាក់ពង្រាយយ៉ាងឆាប់រហ័ស មិនគាំទ្រចំពោះឧបត្តិហេតុបច្ចុប្បន្ននេះទេ ឬ ទាមទារឱ្យមានការវាយតម្លៃបន្ថែមទៀត។ សម្រាប់ការបញ្ជូនបច្ចេកទេសនានាដែលទាមទារឱ្យមានការវាយតម្លៃបន្ថែមទៀតនោះ EPA អាចស្វែងរកព័ត៌មានបន្ថែមទៀត ពីអ្នកលក់ដូរ/អ្នកបញ្ជូនឧបករណ៍បច្ចេកទេស។ ហើយនេះ វាអាចធ្វើទៅបាន ដែលរួមមាន ការធ្វើតេស្តពិសោធន៍ចំពោះសារធាតុពុល ឬ ការធ្វើតេស្តនៅឯទីវាលសម្រាប់លទ្ធភាពដែលអាចធ្វើទៅបាននោះ។

ការឆ្លើយអំពី វិទ្យាសាស្ត្រដ៏ល្អ។

ហើយនេះ វាមានសារៈសំខាន់ណាស់ ដែលថា បច្ចេកទេសថ្មីៗនានា ត្រូវបានគេវាយតម្លៃដោយសមរម្យ សម្រាប់ផលប៉ះពាល់បរិស្ថានដែលជាសក្តានុពល។ នៅក្រោមច្បាប់ទឹកស្អាត ផលិតផលមួយចំនួន ដែលរួមមានសារធាតុគីមី ដូចជា ធាតុខាប់ឬហ្គាសដែលដាក់ឱ្យធាតុផ្សេងទៀតថយចេញ ឬ ធាតុជីវសាស្ត្រនានា ដែលប្រើប្រាស់សរីរាង្គ (សត្ត និង រុក្ខជាតិ) ដែលតូចៗបំផុត ដើម្បីស៊ី ឬ ដាក់បន្សាបជាតិគីមីនានានៅក្នុងបរិស្ថាន ត្រូវតែចុះបញ្ជីឈ្មោះក្នុង ផែនការយថាហេតុថ្នាក់ជាតិ (NCP) សម្រាប់កម្មវិធីផលិតផល មុននឹងប្រើប្រាស់ទឹករបស់អាមេរិក។ ដំណើរការនៃការចុះបញ្ជី NCP ត្រូវធានាថា ដំណោះស្រាយថ្មីៗមានមូលដ្ឋានជាលក្ខណៈវិទ្យាសាស្ត្រ។ NCP រង់ចាំជាស្រេចដើម្បីជួយយឧស្សាហករនានា តាមរយៈដំណើរការនៃ NCP នេះ និង ដើម្បីត្រួតពិនិត្យឡើងវិញនូវការបញ្ជូនបច្ចេកទេសនានាយ៉ាងឆាប់រហ័ស។

បញ្ជូនដំណោះស្រាយផ្នែកបច្ចេកទេសរបស់លោកអ្នក

ប្រសិនណាលោកអ្នក មានដំណោះស្រាយផ្នែកបច្ចេកទេសដែលអាចធ្វើទៅបាននោះ សូមលោកអ្នកបញ្ជូនសំណើរសុំរបស់លោកអ្នក ជូនដល់ IATAP សម្រាប់ការត្រួតពិនិត្យឡើងវិញ សូមមើលលើគេហទំព័ រ www.epa.gov/bpspill/techsolution។

ដំណើរការរបស់ IATAP គឺផ្អែកលើសេក្តីប្រកាសនៃក្រុមទីភ្នាក់ងារ ដែលសុំការបញ្ជូនគំនិតយោបល់នានាពីវិស័យសាធារណៈ នៅក្នុងទម្រង់ជាក្រដាសពណ៌ស ហើយត្រូវបានគេប្រើប្រាស់វាដើម្បីរៀបចំ និង គ្រប់គ្រងគំនិតយោបល់នានា និង ជំនួយបច្ចេកទេសដែលផ្តល់ជូន។

ប្រសិនណា បានផ្តល់ជូនការបញ្ជូនបច្ចេកទេសរួចហើយ ក្រោមប្រព័ន្ធមុនៗនេះ លោកអ្នកមិនត្រូវការបញ្ជូនឡើងវិញ តាមរយៈគេហទំព័ រ IATAP នោះឡើយ។ ការបញ្ជូនបច្ចេកទេសទាំងនោះ ដែលត្រូវបានគេកំណត់នៃការឆ្លើយតបចំពោះស្ថានភាពនេះ បានត្រូវគេចែករំលែកជាមួយក្រុមអ្នកធ្វើសម្រេចចិត្ត នៅក្នុងក្រុមសន្តិសុខឆ្នេរសមុទ្រសហរដ្ឋអាមេរិក និង/ឬ ក្រុមហ៊ុនប្រេងអង់គ្លេស BP។

ដោយសារទំហំនៃការបញ្ជូនបច្ចេកទេសនានា វាមានការលំបាកចំពោះ IATAP ដើម្បីផ្តល់ជូននូវទិន្នន័យឬព័ត៌មានថ្មីៗដែលពាក់ព័ន្ធនឹងស្ថានភាពនៃការបញ្ជូនបច្ចេកទេសរបស់លោកអ្នក ដូចដែលគំនិតយោបល់របស់លោកអ្នកទៅតាមរយៈដំណើរការត្រួតពិនិត្យឡើងវិញរវាងក្រុមទីភ្នាក់ងារនេះ។ លោកអ្នក នឹងត្រូវបានផ្តល់ជូនព័ត៌មានប្រសិនបើ ដំណោះស្រាយបច្ចេកទេសរបស់លោកអ្នក ត្រូវបានគេទទួលយកសម្រាប់ការប្រើប្រាស់នោះ។

សម្រាប់ព័ត៌មានបន្ថែម

ការព្យាយាមស្តារឱ្យបាននូវសភាពដើមវិញ: www.restorethegulf.gov

ការឆ្លើយតប EPA & លទ្ធផលខ្យល់នៃបរិស្ថានដែលមានសុពលភាព និង ទឹកដែលជាឧទាហរណ៍: www.epa.gov/bpspill

ការឆ្លើយតប CDC: emergency.cdc.gov/gulfoilspill2010

សេវាកម្មឧទ្យានជាតិ: (ទិន្នន័យឬព័ត៌មានថ្មីៗ អំពី ការបិទឧទ្យាន ធនធាននានាដែលជាសក្តនុពលប្រឈមមុខគ្រោះថ្នាក់ និង សកម្មភាព NPS ដើម្បីការពារបរិវេណឧទ្យាន និង សត្វព្រៃសំខាន់ៗ) www.nps.gov/aboutus/oil-spill-response.htm

សេវាកម្មត្រី និង សត្វព្រៃ: (ទិន្នន័យឬព័ត៌មានថ្មីៗ តាមឆ្នេរឈូងសមុទ្រ និង ស្ថានភាពភាសខ្លួនសត្វព្រៃជាតិ) www.fws.gov/home/dhoilspill

សេវាកម្មនេសាទ NOAA: (ទិន្នន័យឬព័ត៌មានថ្មីៗប្រចាំថ្ងៃ អំពីការបិទការនេសាទ) sero.nmfs.noaa.gov

សូមហៅទូរស័ព្ទមកមជ្ឈមណ្ឌល

មជ្ឈមណ្ឌលព័ត៌មានរួម: (713) 323-1670 ឬ (713) 323-1671

ឧបត្ថម្ភគាំទ្រខាងសុខាភិបាល/ត្រួតពិនិត្យជាតិពុល: (សម្រាប់សំណួរនានាដែលទាក់ទងនឹងសុខភាពនៃការធ្លាយហៀរប្រេង) (800) 222-1222

រាយការណ៍អំពី ទឹកដីជាប់នឹងមាត់ទឹកដែលមានប្រេងហៀរ ឬ ស្នើសុំព័ត៌មានសម្រាប់អ្នកស្ម័គ្រចិត្ត: (866) 448-5816

បញ្ជូនបច្ចេកទេសឆ្លើយតប សេវាកម្ម ឬ ផលិតផលនានាដែលមានជម្រើស: (281) 366-5511

បញ្ជូននាវារបស់លោកអ្នក សម្រាប់ឱកាសកម្មវិធីនាវា: (866) 279-7983

បញ្ជូនការបញ្ជាក់អះអាង ទាមទារសំណងពីការខូចខាតនានា: (800) 440-0858

រាយការណ៍អំពី សត្វព្រៃដែលរងគ្រោះពីប្រេងហៀរ: (866) 557-1401